ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពជំនាញការពាររុក្ខជាតិ

# សេចក្តីជូនដំណឹងសំខាន់ៗ

## អំពីទំនិញប្រៃសណីយ៍អន្តរជាតិ

**ទំនិញហាមឃាត់នាំចូល និងទំនិញមិនអនុលោម នឹងត្រូវបោះចោលដោយគ្មានការជូនដំណឹងជាមុន ដោយអនុវត្តតាមច្បាប់ការពាររុក្ខជាតិ។**

ចំពោះរុក្ខជាតិនាំចូលជាទំនិញប្រៃសណីយ៍អន្តរជាតិ ដែលត្រូវបានវិនិច្ឆ័យចូលជាប្រភេទណាមួយក្នុងចំណោមខាងក្រោមផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ នឹងត្រូវបានបោះចោលភ្លាមៗដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អ្នកផ្ញើ ឬអ្នកទទួល អនុលោមតាមច្បាប់ការពាររុក្ខជាតិ។

1. ទំនិញហាមឃាត់នាំចូល
   (1) រុក្ខជាតិដែលត្រូវបានហាមឃាត់មិនឱ្យនាំចូលមកក្នុងប្រទេសជប៉ុន(សូមមើលខាងខ្នង)
   (2) ដីឬរុក្ខជាតិដែលមានដីជាប់
   (3) សត្វល្អិតចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
2. ទំនិញមិនអនុលោម
   (1) រុក្ខជាតិដែលគ្មានវិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary certificate) ដែលចេញដោយស្ថាប័នរដ្ឋនៃប្រទេសនាំចេញ(សូមមើលខាងខ្នង)
   (2) រុក្ខជាតិដែលមានជាប់សត្វល្អិតចង្រៃជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

ក្នុងករណីអ្នកបាននាំយកទំនិញហាមឃាត់នាំចូល ឬរុក្ខជាតិចូលមកដោយខុសច្បាប់ របស់ទាំងនោះនឹងត្រូវបោះចោល ដោយផ្អែកលើច្បាប់ការពាររុក្ខជាតិ ហើយអ្នកអាចនឹងរងការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ 3ឆ្នាំ ឬពិន័យជាប្រាក់រហូតដល់ 3លានយ៉េន។

**កំពុងប្រុងប្រយ័ត្នលើការឈ្លានពានចូលនៃសត្វល្អិតចង្រៃពីរុក្ខជាតិ**

MAFF
Ministry of Agriculture, Forestry and Fisheries
農林水産省

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពជំនាញការពាររុក្ខជាតិ

## រុក្ខជាតិសំខាន់ៗដែលត្រូវបានហាមឃាត់មិនឱ្យនាំចូលមកប្រទេសជប៉ុន

- ផ្លែឈើ និងបន្លែភាគច្រើន(ដូចជាផ្លែស្វាយ និងប្រភេទក្រូចជាដើម) មកពីប្រទេស នឹងតំបន់ដែលមានសត្វរុយផ្លែឈើមេឌីទែរ៉ាណេ និងរុយបាក់ត្រូសេរ៉ា ឌ័រសាលីស។
- គ្រាប់វ៉លណាត់ទាំងសំបកជាដើមមកពីប្រទេស និងតំបន់ដែលមានដង្កូវcodling moth
- ក្រៅពីនេះ រុក្ខជាតិជាច្រើនត្រូវបានហាមឃាត់មិនឱ្យនាំមកពីប្រទេស និងតំបន់ដែលមានសត្វល្អិតចង្រៃដែលមិនទាន់មាននៅក្នុងប្រទេសជប៉ុន ប៉ុន្តែកំពុងបង្កការខូចខាតធ្ងន់ធ្ងរនៅលើពិភពលោក។

សម្រាប់ព័ត៌មានលម្អិត សូមសាកសួរទៅអង្គភាពជំនាញការពាររុក្ខជាតិ។


ស្វាយ


ប្រភេទក្រូច


ត្របែក


ម្ទេស


វ៉លណាត់ទាំងសំបក

## រុក្ខជាតិដែលត្រូវការវិញ្ញាបនបត្រភូតគាមអនាម័យ

- ក្រៅពីផ្លែឈើ បន្លែ និងគ្រាប់ធញ្ញជាតិជាដើម ក៏រួមបញ្ចូលផងដែរនូវ ទងផ្កា គ្រាប់ពូជ សំណាប និងផលិតផលកែច្នៃមួយចំនួនដែលធ្វើពីរុក្ខជាតិផងដែរ។
- ប្រភេទគ្រាប់ធញ្ញជាតិ(អង្ករ ស្រូវមីយេ ពោត buckwheat ស្រូវសាលី។ល។) ប្រភេទសណ្តែក (សណ្តែកសៀង សណ្តែកក្រហម សណ្តែកដី។ល។) ឈើ សណ្តែកកាកាវ គ្រាប់ល្ង ផ្លែអំពិលស្ងួត ដីវ៉ាន់ស៊ុយ រឺឯផ្កាស្ងួត/ឱសថបុរាណ/គ្រឿងទេសជាដើមទោះបីស្ងួតក៏ដោយ ត្រូវមានភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រភូតគាមអនាម័យ។

សម្រាប់ព័ត៌មានលម្អិត សូមសាកសួរទៅអង្គភាពជំនាញការពាររុក្ខជាតិ។


អង្ករ


ស្រូវមីយេ


សណ្តែកសៀង


សណ្តែកដី


ផ្លែអម្ពិលស្ងួត

## លេខទំនាក់ទំនងចម្បងនៃអង្គភាពជំនាញការពាររុក្ខជាតិ

- អង្គភាពជំនាញការពាររុក្ខជាតិយ៉ូកូហាម៉ា 045−211−7153
- អង្គភាពជំនាញការពាររុក្ខជាតិណាហ្គោយ៉ា 052−651−0132
- អង្គភាពជំនាញការពាររុក្ខជាតិកូបិ 078−331−2376
- អង្គភាពជំនាញការពាររុក្ខជាតិម៉ុជិ 093−321−2601
- អង្គភាពជំនាញការពាររុក្ខជាតិណាហា 098−868−2850

សូមចុចទីនេះសម្រាប់គេហទំព័ររបស់អង្គភាពជំនាញការពាររុក្ខជាតិ